Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# កិច្ចសហប្រតិបត្តិការធនធានទឹកឆ្លងដែន និងការពិនិត្យតាមដាន លើផលប៉ះពាល់បរិស្ថានទទួលបានការគាំទ្រពីប្រទេសអាល្លឺម៉ង់

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ –** ថ្ងៃនេះ រដ្ឋាភិបាលប្រទេសអាល្លឺម៉ង់បានផ្តល់ថវិកាបន្ថែមចំនួន ២លានអឺរ៉ូ (ប្រមាណ២.២លានដុល្លារអាមេរិក) ឲ្យទៅគណៈកម្មការទន្លេមេគង្គ (ដែលហៅកាត់ថា MRC) ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងកិច្ចសន្ទនាធនធានទឹកឆ្លងដែន និងផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានា ក្នុងការពិនិត្យតាមដានផលប៉ះពាល់បរិស្ថានឆ្លងដែនពីទំនប់វារីអគ្គិសនីតាមដងទន្លេនៃទន្លេមេគង្គក្រោម។

កិច្ចព្រមព្រៀងផ្តល់ថវិកានេះត្រូវបានចុះហត្ថលេខាដោយលោកបណ្ឌិត អាន ពេជ្រហត្ថដា នាយកប្រតិបត្តិលេខាធិការដ្ឋាន MRC និងលោក យិនស៍ លុធឃិនហែម (Jens Lütkenherm) ឯកអគ្គរដ្ឋទូតប្រទេសអាល្លឺម៉ង់ប្រចាំប្រទេសឡាវ ក្នុងពិធីចុះហត្ថលេខាដែលបានប្រព្រឹត្តទៅនៅទីក្រុងវៀងចន្ទ នាថ្ងៃទី១៣ ខែធ្នូ។ មូលនិធិបន្ថែមនេះ បានធ្វើឲ្យការចូលរួមចំណែកថវិការបស់ប្រទេសអាល្លឺម៉ង់សម្រាប់MRC កើនដល់ចំនួន៦.៤៥លានអឺរ៉ូសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របច្ចុប្បន្ន ឆ្នាំ២០១៦-២០២០ និងការចាប់ផ្តើមផែនការថ្មី ឆ្នាំ២០២១-២០២៥។

ក្នុងន័យបញ្ជាក់ជាថ្មីពីភាពជាដៃគូដ៏យូរអង្វែងរបស់ប្រទេសអាល្លឺម៉ង់នឹងគណៈកម្មការទន្លេមេគង្គ មូលនិធិនេះមានគោលបំណងជំរុញកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការលើការរៀបចំផែនការ និងគ្រប់គ្រងធនធានទឹកឆ្លងដែនក្នុងចំណោមប្រទេសតាមដងទន្លេមេគង្គក្រោម ដែលរួមមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។

សម្រាប់រយៈពេល៣ឆ្នាំ (២០១៩-២០២១) ជំនួយឥតសំណងនេះ មានគោលបំណងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែង ក្នុងការពិនិត្យតាមដានផលប៉ះពាល់បរិស្ថានឆ្លងដែន ពីទំនប់វារីអគ្គិសនីតាមដងទន្លេមេដែលបានសាងសង់រួចរាល់ក្នុងទន្លេមេគង្គក្រោមរួមមានទំនប់សាយ៉ាបូរី និងដនសាហុង និងផ្តល់នូវវិធាននានា ដើម្បីកាត់បន្ថយផលប៉ះពាល់តាមរយៈកម្មវិធីពិនិត្យតាមដានបរិស្ថានរួមរបស់ MRC។

លោកបណ្ឌិត ហត្ថដា បានលើកឡើងថា "ការគាំទ្ររបស់ប្រទេសអាល្លឺម៉ង់មកដល់ចំពេលដ៏សំខាន់ គឺពេលដែលទន្លេមេគង្គកំពុងប្រឈមនឹងការប្រឹងប្រែងដ៏ពិបាក រវាងការបង្កើនការអភិវឌ្ឍក្នុងវិស័យថាមពល ដឹកជញ្ជូន និងកសិកម្ម និងផលប៉ះពាល់លើបរិស្ថាន និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងស្រុក។"

យោងតាមលទ្ធផលការពិនិត្យតាមដានលំហូរទឹករបស់ MRCចុងក្រោយបំផុតបានបង្ហាញថា គ្រោះរាំងស្ងួតឆ្នាំ២០១៩ បានបណ្តាលឲ្យកម្រិតទឹកទន្លេមេគង្គធ្លាក់ដល់កម្រិតទាបបំផុតនៅក្នុងប្រវត្តិសាស្រ្ត ឬក្នុងកំឡុងពេល៦០ឆ្នាំចុងក្រោយនេះ។ តំបន់ភាគច្រើនតាមអាងទន្លេ កំពុងជួបប្រទះនូវលំហូរទឹកទាបគួរឲ្យកត់សម្គាល់ ចាប់តាំងពីខែមិថុនាមក។

លទ្ធផលបានបង្ហាញបន្ថែមថា លំហូរទឹកទាបខ្លាំង ការធ្លាក់ចុះឃើញនៃសារជាតុកករ និងវត្តមានសារាយឬស្លែនៅលើដីខ្សាច់ និងស្រទាប់បាតទន្លេ គឺជាមូលហេតុដែលបណ្តាលឲ្យពណ៌ទឹកទន្លេមេគង្គប្រែជាពណ៌ខៀវបៃតងនាពេលថ្មីៗនេះ។ MRCបានក្រើនរំលឹកថា ស្ថានភាពទឹកប្រែពណ៌ខៀវបៃតង អាចនឹងកើតមាននៅតាមកន្លែងផ្សេងៗទៀត និងបង្កឲ្យមានហានិភ័យ ដូចជាការប្រែប្រួលផលិតភាពរបស់ទន្លេ ការកាត់បន្ថយផលិតភាពជីវៈសាស្រ្តចម្រុះក្នុងទឹក ដែលបណ្តាលមកពីទឹកប្រែកាន់តែថ្លាច្បាស់។

លោកបណ្ឌិត ហាត្តដា បានបន្ថែមថា "បញ្ហាដែលកំពុងកើតមានទាំងនេះ ទាមទារឲ្យមានការពិនិត្យតាមដាន និងរាយការណ៍ល្អិតល្អន់ និងរហ័សសម្រាប់ការគ្រប់គ្រងអាងទន្លេដ៏សមស្របមួយ។ ខ្ញុំសូមអរគុណដល់ប្រទេសអាល្លឺម៉ង់ដែលបានធ្វើឲ្យកិច្ចការនេះអាចអនុវត្តបាន។"

ប្រទេសអាល្លឺម៉ង់ បានផ្តល់មូលនិធិគាំទ្រដល់MRC ទាំងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញប្បទានគិតជាថវិកាប្រមាណជិត ៥០លានអឺរ៉ូ ចាប់តាំងពីឆ្នាំ១៩៩៥មក។ ការគាំទ្ររបស់ប្រទេសអាល្លឺម៉ង់ទាំងនេះបានផ្តល់លទ្ធភាពឲ្យMRC អនុវត្តនូវសកម្មភាពយុទ្ធសាស្រ្តផ្សេងៗ រួមមានកំណែទម្រង់ស្ថាប័ន ការអភិវឌ្ឍថាមពលវារីអគ្គិសនីប្រកបដោយចីរភាព ការគ្រប់គ្រងធនធានទឹករួម ការកាត់បន្ថយគ្រោះទឹកជំនន់ និងបម្រែបម្រួលអាកាសធាតុ។

លោក យិនស៍ លុធឃិនហែម (Jens Lütkenherm) បានលើកឡើងថា "នៅពេលដែលទន្លេមេគង្គកំពុងរងនូវសម្ពាធពីផលប៉ះពាល់នៃគម្រោងគ្រប់គ្រងទឹកសម្រាប់ប្រព័ន្ធធារាសាស្រ្ត ថាមពលវារីអគ្គិសនី និងការផ្គត់ផ្គង់ទឹក ក្នុងពេលតែមួយ កិច្ចការរបស់MRC នឹងប្រែកាន់តែសំខាន់ ក្នុងការពិនិត្យតាមដាន និងគ្រប់គ្រងបម្រែបម្រួលរបស់អាងទន្លេ។"

"ថវិកាបន្ថែមរបស់យើងនឹងផ្តល់លទ្ធភាពដល់MRC ពន្លឿនកិច្ចការវាយតម្លៃផលប៉ះពាល់ទាំងនោះ និងជានាថាភាគីដែលធ្វើការសម្រេចចិត្តទាំងអស់នៅក្នុងអាងទន្លេបានយល់ដឹងពីផលវិបាកនានា និងចាត់វិធានការឲ្យបានសមស្រប និងទាន់ពេលវេលា។"

## កំណត់សម្គាល់សម្រាប់និពន្ធនាយកៈ

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និង

វៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្ត្រ
មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263, ភ្ជាប់បន្ត 4012
ទូរសព្ទដៃ៖ +856-20-77779168

###